# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.........[illegible]/២២.........ក.ប/[illegible]

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

យោងច្បាប់ស្តីពីការងារ និងប្រកាសលេខ៣៥៨/២១ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយករោងចក្រ សហគ្រាសដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា លោក/លោកស្រី មានកាតព្វកិច្ចស្វ័យប្រកាសអធិការកិច្ចការងារក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចំនួន ២ (ពីរ) លើកក្នុងមួយឆ្នាំ គឺលើកទី១ ឱ្យបានមុនដំណាច់ខែមិថុនា និងលើកទី២ ឱ្យបានមុនដំណាច់ខែធ្នូ នៃឆ្នាំនីមួយៗ តាមរយៈគេហទំព័រ៖ https://sicms.mlvt.gov.kh ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។

ក្នុងរបាយការណ៍ស្វ័យប្រកាសអធិការកិច្ចការងារមានចំណុចអាទិភាពចំនួន៣១ ដែលមានកំណត់នៅក្នុងលិខិតដាក់កំហិតរបស់អធិការការងារ ម្ចាស់ ឬនាយករោងចក្រ សហគ្រាសត្រូវអនុវត្តឱ្យខានតែបានតាមលិខិតដាក់កំហិតនេះ ក្នុងករណីល្មើសនឹងចំណុចអាទិភាពណាមួយនឹងត្រូវទទួលរងការដាក់ពិន័យភ្លាមៗពីអធិការការងារយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងសូមក្រើនរំលឹកដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាសឱ្យបានជ្រាបថាការចាក់វ៉ាក់សាំងកូវីដ-១៩ ជាផ្នែកមួយនៃលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅតាមរោងចក្រ សហគ្រាស។ ដូច្នេះ លោក/លោកស្រី ត្រូវបន្តសហការជាមួយអាជ្ញាធរមូលដ្ឋានរាជធានី ខេត្ត និងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ដើម្បីជំរុញ និងរៀបចំចាក់វ៉ាក់សាំងដូសជំរុញ ជូនបងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ដោយអាចបន្តដំណើរការផលិតកម្ម/អាជីវកម្មតាមធម្មតា ព្រមទាំងត្រូវបំពេញព័ត៌មាននៃការចាក់វ៉ាក់សាំងក្នុងរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មតាមរយៈគេហទំព័រខាងលើ។ អធិការការងារ នឹងចុះធ្វើអធិការកិច្ចការងារពិសេស ដើម្បីត្រួតពិនិត្យទិន្នន័យកម្មករនិយោជិតចាក់វ៉ាក់សាំងកូវីដ-១៩។

ក្នុងករណីម្ចាស់ ឬនាយករោងចក្រ សហគ្រាសមិនបានធ្វើរបាយការណ៍ស្វ័យប្រកាសអធិការកិច្ចការងារ តាមកាលកំណត់ និងមិនព្រមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ត្រូវទទួលការពិន័យ ឬផ្តន្ទាទោសតាមច្បាប់ និងការចាត់វិធានការតាមផ្លូវច្បាប់ពីក្រសួង។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាសទាំងអស់អនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**

លេខ:..២៥៩/២២..ក.ប/អ.ក/អ.ធ.ក.

# លិខិតដាក់កំហិត

## ជម្រាបមក

## លោក លោកស្រី ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ស្ថិតក្នុងផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប

**កម្មវត្ថុ ៖** ការដាក់កំហិតស្តីពីការអនុវត្តបែបបទស្តីពីសហគ្រាស លក្ខខណ្ឌទូទៅនៃការងារ លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ លក្ខខណ្ឌនៃបេឡាជាតិសន្តិសុខសង្គម និងលក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ។

**យោង ៖** -ច្បាប់ស្តីពីការងារ

-ប្រកាសលេខ៣៥៨/២១ ក.ប/ប្រ.ក.អ.ធ.ក. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

-សេចក្តីជូនដំណឹងលេខ ០២២/២២ ក.ប/ស.ជ.ណ.អ.ធ.ក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ស្តីពីការអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូម **លោក លោកស្រី** មេត្តាអនុវត្តឱ្យបានរួចស្រេចអំពីបែបបទស្តីពីសហគ្រាស និងឱ្យបានត្រឹមត្រូវតាមច្បាប់នូវលក្ខខណ្ឌទូទៅនៃការងារ លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ លក្ខខណ្ឌនៃបេឡាជាតិសន្តិសុខសង្គម និងលក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ ខាងក្រោមចាប់ពីពេលនេះតទៅ៖

**ក.បែបបទស្តីពីសហគ្រាស**

១-ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

-ត្រូវបិទផ្សាយបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

**ខ.លក្ខខណ្ឌទូទៅនៃការងារ**

១-ត្រូវផ្តល់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសាកល្បងការងារឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតពេញសិទ្ធិឱ្យបានត្រឹមត្រូវ

២-ត្រូវផ្តល់ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ ២០១៩ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៣-ត្រូវផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាមានថិរវេលាកំណត់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៤-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងនៅពេលយប់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៥-មិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសថិរវេលាកំណត់

៦-មិនត្រូវមានការរើសអើងពេលជ្រើសរើសកម្មករនិយោជិតចូលធ្វើការ

-ត្រូវផ្តល់ប្រាក់ឈ្នួលឱ្យស្មើគ្នា ចំពោះការងារដែលមានលក្ខខណ្ឌដូចគ្នា មានភាពប៉ិនប្រសប់ខាងវិជ្ជាជីវៈដូចគ្នា និងផលដែលធ្វើបានស្មើគ្នា



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៧-មិនត្រូវឱ្យកម្មករនិយោជិតធ្វើការដើម្បីកាត់ប្រាក់ជំពាក់
-មិនត្រូវឱ្យកម្មករនិយោជិតធ្វើការដោយគ្មានប្រាក់ឈ្នួល
៨-មិនត្រូវឱ្យមានកម្មករនិយោជិតទទួលរងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ
៩-ត្រូវរក្សាទុកអតីតភាពការងាររបស់កម្មករនិយោជិតជាស្ត្រី ក្នុងពេលសម្រាកលំហែមាតុភាព
១០-មិនត្រូវបញ្ឈប់កម្មករនិយោជិតជាស្ត្រីដែលមានផ្ទៃពោះ ឬឈប់សម្រាលកូន ឬបង្ខំឱ្យលាឈប់ពីការងារ
១១-ត្រូវធ្វើលិខិតអនុញ្ញាតឱ្យប្រើប្រាស់ក្មេងដែលមានអាយុក្រោម១៨ឆ្នាំឱ្យបានត្រឹមត្រូវ
-មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំ ធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬប្រភេទការងារ និងមុខរបរដែលប៉ះពាល់ដល់សុខភាព សន្តិសុខការងារ ឬសីលធម៌របស់ក្មេង
-មិនត្រូវឱ្យក្មេងអាយុចាប់ពី១៥ឆ្នាំដល់តិចជាង១៨ឆ្នាំធ្វើការនូវប្រភេទការងារប្រកបដោយគ្រោះថ្នាក់
-មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំធ្វើការលើសចិរវេលាកំណត់
-មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំធ្វើការលើសចិរវេលាកំណត់ក្នុង១សប្តាហ៍
-ត្រូវឱ្យកម្មករនិយោជិតវ័យក្មេងឈប់សម្រាកប្រចាំសប្តាហ៍ឱ្យបានត្រឹមត្រូវ
-ត្រូវរៀបចំឱ្យមានសៀវភៅបញ្ជីចុះនាមក្មេងអាយុក្រោម១៨ឆ្នាំឱ្យបានត្រឹមត្រូវ
-មិនត្រូវឱ្យកម្មករនិយោជិតវ័យក្មេងធ្វើការនៅពេលយប់ពីម៉ោង២២:០០ ដល់ម៉ោង៥:០០ភ្លឺ
១២-ត្រូវធ្វើលិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសប្រចាំឆ្នាំ
១៣-ត្រូវរៀបចំប័ណ្ណការងារនិងសៀវភៅការងារជូនកម្មករនិយោជិតខ្មែរឱ្យបានត្រឹមត្រូវ

**គ.លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ**

១-ត្រូវរៀបចំការផ្តល់ភេសជ្ជៈអនាម័យ/ទឹកស្អាតឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ដល់កម្មករនិយោជិត
២-ត្រូវរៀបចំប្រអប់សង្គ្រោះប្រចាំរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ
៣-ត្រូវរៀបចំបន្ទប់រំរួសប្រចាំរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ
៤-ត្រូវអនុវត្តនូវវិធានសុវត្ថិភាពការងារឱ្យបានត្រឹមត្រូវ ដើម្បីបង្ការគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ
៥-ត្រូវរៀបចំប្រព័ន្ធបញ្ចេញ បញ្ចូលខ្យល់នៅក្នុងអគារឱ្យសមស្របតាមបទដ្ឋានដែលបានកំណត់
៦-ត្រូវរៀបចំច្រកគ្រាអាសន្នទាំងអស់អាចចេញដោយសុវត្ថិភាព មានភាពធំទូលាយ គ្មានអ្វីមកបាំង និងមិនចាក់សោរ
៧-ត្រូវរៀបចំវិធានការការពារទុកជាមុនសម្រាប់ទប់ស្កាត់ហេតុការណ៍ដែលកើតដោយយថាហេតុ
-ត្រូវរៀបចំចាត់តាំងអ្នកទទួលខុសត្រូវនៅពេលមានអាសន្ន
៨-ត្រូវរៀបចំការអប់រំបណ្តុះបណ្តាលអំពីកាយវិការ អាកប្បកិរិយានៅពេលមានអាសន្ន និងនៅពេលជួយសង្គ្រោះគ្នា ឬបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់
៩-ត្រូវបិទសញ្ញាការសុវត្ថិភាពនិងសុខភាពការងារឱ្យបានគ្រប់គ្រាន់នៅតាមប៉ុស្តិ៍ការងារ និងនៅតាមទីតាំងផ្សេង
១០-ត្រូវមានការត្រួតពិនិត្យ និងអនុវត្តការសាកល្បងប្រើប្រាស់ជាក់ស្តែងនូវប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យឱ្យបានយ៉ាងហោចណាស់ក្នុងរយៈពេល ០១ខែម្តង
-ត្រូវមានការត្រួតពិនិត្យតាមលក្ខណបច្ចេកទេសទៅលើបំពង់ពន្លត់អគ្គិភ័យឱ្យបានត្រឹមត្រូវ
-ត្រូវទុកដាក់ និងថែទាំឧបករណ៍ពន្លត់អគ្គិភ័យឱ្យបានត្រឹមត្រូវ
១១-ត្រូវរៀបចំឡចំហាយ និងអនុវត្តការប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេសនិងសុវត្ថិភាពការងារ
១២-ត្រូវប្រើប្រាស់គ្រឿងម៉ាស៊ីន ឬគ្រឿងយន្តឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេស និងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ
-ត្រូវរៀបចំទីតាំងដាក់គ្រឿងម៉ាស៊ីនឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេសក្នុងការការពារកុំឱ្យមានគ្រោះថ្នាក់ ឬហានិភ័យការងារ
-ត្រូវរៀបចំបំពាក់ឧបករណ៍ការពារដើម្បីធានាសុវត្ថិភាពកម្មករនិយោជិត
-ត្រូវរៀបចំការចាត់តាំងអ្នកគ្រប់គ្រងទទួលខុសត្រូវក្នុងការបញ្ជាប្រើប្រាស់គ្រឿងម៉ាស៊ីន និងគ្រឿងយន្ត
-ត្រូវរៀបចំការថែទាំ និងជួសជុលគ្រឿងម៉ាស៊ីនជាប្រចាំ

**ឃ.លក្ខខណ្ឌនៃរបបសន្តិសុខសង្គម**

១-ត្រូវរៀបចំចុះបញ្ជិកាពោងចក្រ សហគ្រាសនៅបេឡាជាតិសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ

២-ត្រូវរៀបចំចុះបញ្ជិកាកម្មករនិយោជិតនៅបេឡាជាតិសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ

៣-ត្រូវបង់ភាគទានឱ្យកម្មករនិយោជិតផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពឱ្យបានត្រឹមត្រូវ

**ង.លក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ**

១-ត្រូវរៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក

-ត្រូវអនុវត្តតាមប្រកាសស្តីពីប្រតិភូបុគ្គលិកនៅក្នុងរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

២-មិនត្រូវបង្ខិតបង្ខំកម្មករនិយោជិតឱ្យចូលរួម និងមិនចូលរួមនៅក្នុងសហជីព

-មិនត្រូវបង្ខិតបង្ខំកម្មករនិយោជិតឱ្យចូលរួម និងមិនចូលរួមវិវាទការងារ

**លោក លោកស្រី** ត្រូវអនុវត្តឱ្យខានតែបានតាមលិខិតដាក់កំហិតនេះ ក្នុងករណីល្មើសនឹងចំណុចអាទិភាពណាមួយនឹងត្រូវទទួលរងការផាកពិន័យភ្លាមៗពីអធិការការងារយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ **លោក លោកស្រី** ត្រូវអនុវត្តតាមការដាក់កំហិតឱ្យបានត្រឹមត្រូវតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សូម **លោក លោកស្រី** ទទួលនូវសេចក្តីរាប់អានពីខ្ញុំ។

ថ្ងៃ ចន្ទ ១៤រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២២

**អធិការការងារ**

**និងជាប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**ខេម ប៊ុនឈាន**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**

លេខ: ១៥៤/២២ ក.ប/អ.ក/អ.ធ.ក.

# លិខិតដាក់កំហិត

**ជម្រាបមក**

**លោក លោកស្រី ម្ចាស់ ឬនាយករោងចក្រ សហគ្រាស**
**ស្ថិតក្រៅផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង**
**និងផលិតផលិតផលធ្វើដំណើរនិងកាបូប**

**កម្មវត្ថុ** ៖ ការដាក់កំហិតស្តីពីការអនុវត្តបែបបទស្តីពីសហគ្រាស លក្ខខណ្ឌទូទៅនៃការងារ លក្ខខណ្ឌសុវត្ថិភាព និង សុខភាពការងារ លក្ខខណ្ឌនៃបេឡាជាតិសន្តិសុខសង្គម និងលក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ។

**យោង** ៖ -ច្បាប់ស្តីពីការងារ

-ប្រកាសលេខ៣៩៨/២១ ក.ប/ប្រ.ក.អ.ធ.ក. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

-សេចក្តីជូនដំណឹងលេខ ០២២/២២ ក.ប/ស.ជ.ណ.អ.ធ.ក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ស្តីពីការអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូម **លោក លោកស្រី** មេត្តាអនុវត្តឱ្យបានរួចស្រេចអំពីបែបបទស្តីពីសហគ្រាស និងឱ្យបានត្រឹមត្រូវតាមច្បាប់នូវលក្ខខណ្ឌទូទៅនៃការងារ លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ លក្ខខណ្ឌនៃបេឡាជាតិសន្តិសុខសង្គម និងលក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ ខាងក្រោមចាប់ពីពេលនេះតទៅ៖

## ក.បែបបទស្តីពីសហគ្រាស

១-ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

## ខ.លក្ខខណ្ឌទូទៅនៃការងារ

១-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់ឈ្នួលថ្ងៃបុណ្យនិងប្រាក់បំណាច់ធ្វើការថ្ងៃឈប់សម្រាកបុណ្យជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

២-ត្រូវផ្តល់ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៣-ត្រូវផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាមានថិរវេលាកំណត់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៤-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការនៅពេលយប់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៥-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៦-ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងនៅពេលយប់ជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៧-មិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសថិរវេលាកំណត់



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៨-ត្រូវមានលិខិតអនុញ្ញាតធ្វើការបន្ថែមម៉ោងពីអធិការការងារ ឬមិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសចិរវេលា ដែលបានអនុញ្ញាត ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត

-ត្រូវមានលិខិតអនុញ្ញាតធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលពីអធិការការងារ ឬមិនត្រូវឱ្យកម្មករនិយោជិតធ្វើការនៅថ្ងៃបុណ្យលើសពីការអនុញ្ញាត ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត

៩-ត្រូវមានលិខិតអនុញ្ញាតព្យួរការឈប់ការសម្រាកប្រចាំសប្តាហ៍ពីអធិការការងារ ឬមិនត្រូវឱ្យកម្មករនិយោជិតធ្វើការលើសចិរវេលាដែលបានអនុញ្ញាត ឬមិនផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត

១០-មិនត្រូវមានការរើសអើងពេលជ្រើសរើសកម្មករនិយោជិតចូលធ្វើការ

១១-មិនត្រូវឱ្យកម្មករនិយោជិតធ្វើការងារដោយបង្ខំ

១២-ត្រូវផ្តល់រយៈពេលនៃការឈប់សម្រាកលំហែមាតុភាពឱ្យបានត្រឹមត្រូវ

-ត្រូវផ្តល់ប្រាក់ឈ្នួលគិតទាំងប្រាក់បន្ទាប់បន្សំនៅពេលឈប់សម្រាកលំហែមាតុភាពឱ្យបានត្រឹមត្រូវ

១៣-មិនត្រូវបញ្ឈប់កម្មករនិយោជិតជាស្ត្រីដែលមានផ្ទៃពោះ ឬឈប់សម្រាលកូន ឬបង្ខំឱ្យលាឈប់ពីការងារ

១៤-ត្រូវធ្វើលិខិតអនុញ្ញាតឱ្យប្រើប្រាស់ក្មេងដែលមានអាយុក្រោម១៨ឆ្នាំឱ្យបានត្រឹមត្រូវ

-មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំ ធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬប្រភេទការងារ និងមុខរបរដែលប៉ះពាល់ដល់សុខភាព សន្តិសុខការងារ ឬសីលធម៌របស់ក្មេង

-មិនត្រូវឱ្យក្មេងអាយុចាប់ពី១៥ឆ្នាំដល់តិចជាង១៨ឆ្នាំធ្វើការនូវប្រភេទការងារប្រកបដោយគ្រោះថ្នាក់

-មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំធ្វើការលើសចិរវេលាកំណត់

-មិនត្រូវឱ្យក្មេងអាយុក្រោម១៨ឆ្នាំធ្វើការលើសចិរវេលាកំណត់ក្នុង១សប្តាហ៍

-ត្រូវឱ្យកម្មករនិយោជិតវ័យក្មេងឈប់សម្រាកប្រចាំសប្តាហ៍ឱ្យបានត្រឹមត្រូវ

១៥-ត្រូវធ្វើលិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសប្រចាំឆ្នាំ

១៦-ត្រូវរៀបចំប័ណ្ណការងារនិងសៀវភៅការងារជូនកម្មករនិយោជិតខ្មែរឱ្យបានត្រឹមត្រូវ

**គ.លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ**

១-ត្រូវរៀបចំទីតាំងដាក់កាកសំណល់ធម្មតាឱ្យបានត្រឹមត្រូវ

២-ត្រូវរៀបចំទីតាំងស្តុកទុកកាកសំណល់សារធាតុគីមី ឬសារធាតុពុល នៅដាច់ដោយឡែក និងមានសុវត្ថិភាព

៣-ត្រូវរៀបចំប្រអប់សង្គ្រោះប្រចាំរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

៤-ត្រូវរៀបចំបន្ទប់រុំរបួសប្រចាំរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

៥-ត្រូវអនុវត្តនូវវិធានសុវត្ថិភាពការងារឱ្យបានត្រឹមត្រូវ ដើម្បីបង្ការគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ

៦-ត្រូវរៀបចំប្រព័ន្ធបញ្ចេញ បញ្ចូលខ្យល់នៅក្នុងអគារឱ្យសមស្របតាមបទដ្ឋានដែលបានកំណត់

៧-ត្រូវរៀបចំច្រកគ្រាអាសន្នទាំងអស់អាចចេញដោយសុវត្ថិភាព មានភាពធំទូលាយ គ្មានអ្វីមកបាំង និងមិនចាក់សោរ

៨-ត្រូវបិទសញ្ញាការសុវត្ថិភាពនិងសុខភាពការងារឱ្យបានគ្រប់គ្រាន់នៅតាមប៉ុស្តិ៍ការងារ និងនៅតាមទីតាំងផ្សេង

៩-ត្រូវរៀបចំឡចំហាយ និងអនុវត្តការប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេសនិងសុវត្ថិភាពការងារ

១០-ត្រូវប្រើប្រាស់គ្រឿងម៉ាស៊ីន ឬគ្រឿងយន្តឱ្យបានត្រឹមត្រូវតាមលក្ខណបច្ចេកទេស និងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ

**ឃ.លក្ខខណ្ឌនៃរបបសន្តិសុខសង្គម**

១-ត្រូវរៀបចំចុះបញ្ជិការោងចក្រ សហគ្រាសនៅបេឡាជាតិសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ

២-ត្រូវរៀបចំចុះបញ្ជិកាកម្មករនិយោជិតនៅបេឡាជាតិសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ

៣-ត្រូវបង់ភាគទានឱ្យកម្មករនិយោជិតផ្អែកហានិភ័យការងារ និងផ្អែកថែទាំសុខភាពឱ្យបានត្រឹមត្រូវ

ង.លក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ

១-ត្រូវរៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក

-ត្រូវអនុវត្តតាមប្រកាសស្តីពីប្រតិភូបុគ្គលិកនៅក្នុងរោងចក្រ សហគ្រាសឱ្យបានត្រឹមត្រូវ

**លោក លោកស្រី** ត្រូវអនុវត្តឱ្យខានតែបានតាមលិខិតដាក់កំហិតនេះ ក្នុងករណីល្មើសនឹងចំណុចអាទិភាពណាមួយនឹងត្រូវទទួលរងការផាកពិន័យភ្លាមៗពីអធិការការងារយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ **លោក លោកស្រី** ត្រូវអនុវត្តតាមការដាក់កំហិតឱ្យបានត្រឹមត្រូវតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សូម **លោក លោកស្រី** ទទួលនូវសេចក្តីរាប់អានពីខ្ញុំ។

ថ្ងៃ ពុធ ១៤រោច ខែ ទុតិយាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០២២

**អធិការការងារ**

**និងជាប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**ខេម ប៊ុនឈាន**